វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

## ឯកសារស្រាវជ្រាវសង្ខេប

ភូមិភាគទី៨ ព្រឹទ្ធសភា

# ទិដ្ឋភាពទូទៅលើការបែងចែក និងទូទាត់ថវិកាថ្នាក់ក្រោមជាតិសម្រាប់ការធ្វើផែនការអភិវឌ្ឍមូលដ្ឋាន

ស្រាវជ្រាវដោយ៖ លោក **ញៀប សីលា** អ្នកភូមិសាស្ត្រនៃវិទ្យាស្ថានសភាកម្ពុជា
លោកស្រី **តុប ដាវី** អ្នកបណ្ដុះបណ្ដាលនៃវិទ្យាស្ថានសភាកម្ពុជា

ខែ តុលា ឆ្នាំ ២០១៩

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗ ដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិកាសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះ មានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

© រក្សាសិទ្ធិ ឆ្នាំ២០១៩ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) ។

# តារាងមាតិកា

I. សេចក្តីផ្តើម....1
II. លទ្ធផលស្រាវជ្រាវ....1
១. តើមានបញ្ហាប្រឈមអ្វីខ្លះ ដែលពាក់ព័ន្ធនឹងការរៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋាននៅថ្នាក់ឃុំ សង្កាត់? ....1
*១.១. ទិដ្ឋភាពទូទៅខេត្តមណ្ឌលគិរី*....1
*១.២. តួនាទី និងមុខងារក្រុមប្រឹក្សាឃុំ សង្កាត់*....2
*១.៣. ទិដ្ឋភាពទូទៅនៃផែនការអភិវឌ្ឍន៍មូលដ្ឋាននៅកម្រិតឃុំ សង្កាត់*....2
២ .តើយន្តការនៃការបែងចែក និងទូទាត់ថវិកា ដើម្បីគាំទ្រដល់ផែនការអភិវឌ្ឍន៍មូលដ្ឋាន និងពង្រឹងការផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិ មានអ្វីខ្លះ? ....3
*២.១. ការរៀបចំផែនការយុទ្ធសាស្រ្តថវិកា*....3
២.២. ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ....4
*២.៣. បញ្ហាប្រឈមនៃការបែងចែកថវិកា*....5
*២.៤. កម្រងច្បាប់ និងក្របខណ្ឌយុទ្ធសាស្រ្តនៃកាកែទម្រង់ប្រព័ន្ធថវិកា*....6
III.សេចក្តីសន្និដ្ឋាន....8
ឯកសារយោង....10

## តារាងរូបភាព

រូបភាព 1៖ វដ្តនៃផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ និងកម្មវិធីអភិវឌ្ឍឃុំ សង្កាត់ .... 3
រូបភាព 2៖ កម្រិតនៃការវិភាជន៍ថវិកាពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ .... 5

## ផែនទី

ផែនទី 1៖ តំបន់រដ្ឋបាលខេត្ត មណ្ឌលគីរី តាម ស្រុក ឃុំ .... 11

## I. សេចក្តីផ្តើម

ឯកសារស្រាវជ្រាវសង្ខេបនេះរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងសំណើររបស់ភូមិភាគទី៨នៃព្រឹទ្ធសភានូវឯកសារជំនួយស្មារតីពី «ទិដ្ឋភាពទូទៅលើការបែងចែក និងទូទាត់ថវិកាថ្នាក់ក្រោមជាតិ សម្រាប់គាំទ្រផែនការអភិវឌ្ឍមូល- ដ្ឋាន»។ ឯកសារនេះ គូសបញ្ជាក់ពីបច្ចុប្បន្នភាពព័ត៌មានជំនួយស្មារតីសំខាន់ៗជាប្រយោជន៍ដល់ការគាំទ្រវេទិកាស្តីពី«ការពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំគម្រោងថវិកា និងការផ្តល់សេវាសាធារណៈ ជូនប្រជា-ពលរដ្ឋ ប្រកបដោយប្រសិទ្ធភាព» នៅខេត្តមណ្ឌលគីរី។

ឯកសារស្រាវជ្រាវសង្ខេបនេះ ពិនិត្យមើលនូវយន្តការបច្ចុប្បន្ន ក្នុងការបែងចែក និងទូទាត់ថវិកានៅថ្នាក់ក្រោមជាតិ ដែលជាមុខងាររបស់រដ្ឋបាលឃុំ/សង្កាត់។ ខ្លឹមសារផ្តោតទៅលើប្រសិទ្ធភាព និងគណនេយ្យភាព នៃការផ្តល់ សេវាសាធារណៈ ដែលជាលទ្ធផលបានមកពីគោលការណ៍ និងការអនុវត្តប្រព័ន្ធបែងចែកថវិកាថ្នាក់ក្រោមជាតិ តាមរយៈការឆ្លើយសំនួរដូចខាងក្រោម៖

១. តើមានបញ្ហាប្រឈមអ្វីខ្លះ ដែលពាក់ព័ន្ធនឹងការរៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋាននៅថ្នាក់ឃុំ សង្កាត់?
២. តើយន្តការនៃការបែងចែក និងទូទាត់ថវិកា ដើម្បីគាំទ្រដល់ផែនការអភិវឌ្ឍន៍មូលដ្ឋាន និងពង្រឹងការ ផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិ មានអ្វីខ្លះ?

របកគំហើញទៅនឹងសំណួរទាំងនេះ បានមកពីការពិនិត្យមើលយ៉ាងល្អិតល្អន់ ឯកសារផ្លូវការដែលមានស្រាប់ និងដែលអាចរកបានពីគេហទំព័ររបស់រដ្ឋាភិបាល និងអង្គការអន្តរជាតិ ដែលអាចជាឯកសាជំនួយស្មារតីគាំទ្រដំណើរការវេទិកានៅខេត្តមណ្ឌលគីរី។

## II. លទ្ធផលស្រាវជ្រាវ

### ១. តើមានបញ្ហាប្រឈមអ្វីខ្លះ ដែលពាក់ព័ន្ធនឹងការរៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋាននៅថ្នាក់ឃុំ សង្កាត់?

#### *១.១. ទិដ្ឋភាពទូទៅខេត្តមណ្ឌលគិរី*

ខេត្តមណ្ឌលគិរី មានវិសាលភាព ១៤.២៨៨ គីឡូម៉ែត្រក្រឡា ស្ថិតនៅតំបន់ភ្នំ ដែលមានស្រុកចំនួន ប្រាំ (ស្រុកកែវសីមា កោះញែក អូររាំង ពេជ្រាដា និង សែនមនោរម្យ) ឃុំចំនួន ២១ និងភូមិចំនួន ៩១ (សូមមើលផែនទី ១ ក្នុងឧបសម្ព័ន្ធ) [1]។ ជំរឿនប្រជាជនឆ្នាំ ២០១៩ បានបង្ហញថា ខេត្តមណ្ឌលគិរីមានប្រជាជនចំនួន ៨៨.៦៤៩ នាក់ ក្នុងចំណោមប្រជាជនសរុបទូទាំងប្រទេសចំនួន ១៥.២៨៨.៤៨៩ នាក់[2] ខណៈដែលឆ្នាំ ២០០៨ ខេត្តនេះមានប្រជា-ជនចំនួន៦១.១០៧ នាក់ប៉ុណ្ណោះ ក្នុងចំណោម ប្រជាជនសរុបចំនួន ១៤.៦៧៦.៥៩១ នាក់[1] ។ នៅក្នុងឆ្នាំ ២០១៩ នេះ ខេត្តមណ្ឌលគិរីមានចំនួនប្រជាជនជាស្ត្រីចំនួន ៤៣.១១៦ (៤៨%)។

ជំរឿនប្រជាជនឆ្នាំ ២០១៩ ក៏បានបង្ហាញផងដែរថា អត្រាកំណើនប្រជាជនប្រចាំឆ្នាំរបស់ខេត្តមណ្ឌលគិរីមាន ចំនួន ៣,៤% ខណៈខេត្តជាប់ព្រំប្រទល់ដូចជាខេត្តក្រចេះមាន ១,៨% ខេត្តស្ទឹងត្រែង ៣,២% និងខេត្តរតនៈគិរី ២,៨% [2, p. 10]។ អត្រាកំណើនប្រចាំឆ្នាំនេះខ្ពស់ដោយសារអត្រាកំណើត និងអត្រាចំណាកស្រុកមកពីខេត្តផ្សេងៗ មានកម្រិតខ្ពស់។

### ***១.២. តួនាទី និងមុខងារក្រុមប្រឹក្សាឃុំ សង្កាត់***

ក្រុមប្រឹក្សាឃុំ/សង្កាត់មានតួនាទីចំនួន៥ [3, 4] គឺ៖ ១). ធានាគុណភាពសេវាកម្មរដ្ឋបាល និងការអភិវឌ្ឍប្រកប ដោយប្រសិទ្ធភាព ២). ធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ៣). លើកកម្ពស់ការអភិវឌ្ឍសង្គម និងសេដ្ឋ-កិច្ចប្រកប ដោយចីរភាព ៤). ការការពារធនធានបរិស្ថាន ធម្មជាតិ និងវប្បធម៌បេតិកភណ្ឌជាតិ និង ៥). ការអនុវត្តកិច្ចការទូទៅដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ បញ្ហាប្រឈមដែលក្រុមប្រឹក្សាឃុំជួបប្រទះអាចកើនឡើងស្របនឹងកំណើនប្រជាជននៅក្នុងខេត្តនេះ។

ក្រុមប្រឹក្សាឃុំ/សង្កាត់ ជួយមេឃុំ/ចៅសង្កាត់ រៀបចំផែនការពាក់ព័ន្ធក៏ដូចជាតាមដាន និងវាយតម្លៃសមិទ្ធិផល ដោយធ្វើការសហការជាមួយផែនការឃុំសង្កាត់ និងគណៈកម្មាធិការអភិវឌ្ឍន៍ថវិកា [5]។ ចាប់តាំងពីឆ្នាំ ២០០២ នៅពេលដែលក្រុមប្រឹក្សាឃុំ/សង្កាត់ ពឹងផ្អែកខ្លាំងទៅលើរដ្ឋាភិបាលថ្នាក់កណ្តាលជាអ្នកផ្តល់ហិរញ្ញប្បទាន ក្រុមប្រឹក្សាឃុំ/សង្កាត់បានរៀបចំថវិការបស់ពួកគេដោយឯករាជ្យ មិនត្រូវការការយល់ព្រមជាមុនពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាឡើយ[6, p.25]។

### ***១.៣. ទិដ្ឋភាពទូទៅនៃផែនការអភិវឌ្ឍន៍មូលដ្ឋានថ្នាក់ឃុំ សង្កាត់***

ក្រុមសិក្សាស្រាវជ្រាវមិនអាចរកបានផែនការអភិវឌ្ឍន៍មូលដ្ឋានរបស់ខេត្តមណ្ឌលគិរី សម្រាប់យកមកសិក្សា និងធ្វើការវិភាគបាននោះទេ។ ទោះជាយ៉ាងណាក៏ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ[3] និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ ឆ្នាំ ២០០៨ [4, p. 9] បានតម្រូវឲ្យក្រុមប្រឹក្សា ឃុំ សង្កាត់ និមួយៗ រៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគរយៈពេលបីឆ្នាំរបស់ខ្លួន។ ច្បាប់ទាំងនេះមានគោលការណ៍បច្ចេកទេសស្តីពីការរៀបចំផែនការ និងការធ្វើផែនការអភិវឌ្ឍន៍ឃុំសង្កាត់ក្នុងកិច្ចខិតខំប្រឹងប្រែងអនុវត្តផែនការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការចូលរួមពេញលេញរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាក់ទងនឹងបញ្ហាបច្ចុប្បន្ន សមធម៌សង្គម ព្រមទាំងការប្រែប្រួលអាកាសធាតុ។

លើសពីនេះទៅទៀត ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ នេះមានសារៈសំខាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីកំណត់នូវបញ្ហា និង តម្រូវការដែលជាអាទិភាពសម្រាប់មូលដ្ឋាន ព្រមទាំងកំណត់នូវយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព ហើយឆ្លើយតបទៅនឹងបញ្ហា និងតម្រូវការជាក់ស្តែងរបស់ពលរដ្ឋ [7, 8, 9]។

ដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍ថ្នាក់ឃុំ/សង្កាត់ មានផែនការការងារពីរធំៗ [7, p. 17, 8]។ ការងារទីមួយ គឺការធ្វើផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់(CDP) រយៈពេល ៥ ឆ្នាំពេញលេញមួយ និងការងារទី២ គឺការពិនិ

ត្យ និងធ្វើបច្ចុប្បន្នភាពកម្មវិធីវិនិយោគឃុំ/សង្កាត់ប្រចាំឆ្នាំ (CIP)[i]។ ដើម្បីរៀបចំ CDP ក្រុមប្រឹក្សាឃុំ/សង្កាត់ គិតពិចារណាពីយុទ្ធសាស្ត្រសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងមិនមែនរូបវន្តដែលឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ [10, 11]។ ដើម្បីបានការគាំទ្រពីដៃគូពាក់ព័ន្ធ និងម្ចាស់ជំនួយដ៏ទៃ ក្រុមប្រឹក្សាត្រូវធ្វើផែនការរបស់ពួកគេទៅដៃគូពាក់ព័ន្ធទាំងនោះដើម្បីសុំការគាំទ្រ [11, 12]។ ដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំសង្កាត់ មានប្រាំជំហាន (សូមមើលរូបភាពទី១ខាងក្រោម) [9]។

*រូបភាព ១៖វដ្តនៃផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ និងកម្មវិធីអភិវឌ្ឍឃុំ សង្កាត់*




*ប្រភព៖ សេចក្តីណែនាំស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ*

ទោះបីជាមានច្បាប់ និងគោលនយោបាយមួយចំនួន ទាក់ទងនឹងការលើកកម្ពស់ ការអនុវត្តន៍ផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ ប៉ុន្តែការរៀបចំផែនការអភិវឌ្ឍន៍ នៅតែជួបនូវបញ្ហាពិបាកមួយចំនួនដូចជា៖

- សមត្ថភាពក្រុមប្រឹក្សា ឃុំ សង្កាត់ ក្នុងការកសាងផែនការ និងការរៀបចំថវិកា នៅមានកម្រិត [7, 9, p. 50]
- កញ្ចប់វិភាជន៍ថវិការទៅកាន់ឃុំ សង្កាត់នៅមានកម្រិតនៅឡើយ [7, 9, p. 50] ឃុំ/សង្កាត់ពឹងផ្អែកលើប្រភពមូលនិធិឃុំ/សង្កាត់ ពីរដ្ឋាភិបាលកណ្តាល។
- កង្វះការចូលរួមពីប្រជាជនក្នុងការកសាងផែនការឃុំ/សង្កាត់ [11, p. 57] ដោយសារតែការយល់ដឹងរបស់ពួកគេលើផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងថវិកា នៅមានកម្រិត ។

## ២. តើយន្តការនៃការបែងចែក និងទូទាត់ថវិកា ដើម្បីគាំទ្រដល់ផែនការអភិវឌ្ឍន៍មូលដ្ឋាន និងពង្រឹងការផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិ មានអ្វីខ្លះ?

### *២.១. ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា*

[i] កម្មវិធីវិនិយោគឃុំ សង្កាត់ គឺជាផែនការប្រចាំឆ្នាំមួយដែលបានរៀបចំសម្រាប់ការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ដើម្បីបំពេញនូវតម្រូវការរបស់សហគមន៍។

ដោយផ្អែកលើ មាត្រា៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ប្រតិទិនសម្រាប់សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ចែកចេញជាបីដំណាក់កាល[ii]។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលបានដាក់ចេញនូវ សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាជាតិ និងសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ក្រោមជាតិ ដើម្បីផ្តល់ជាគោលការណ៍ណែនាំថ្មីៗ និងជាមគ្គុទ្ទេសបច្ចេកទេសគន្លឹះៗ ក្នុងការធ្វើបច្ចុប្បន្នភាព ផែនការយុទ្ធសាស្ត្រថវិកា។ ផែនការយុទ្ធសាស្ត្រថវិកា ជាផែនការបីឆ្នាំរំកិលតាមអភិក្រមពីក្រោមឡើងលើ រៀបចំជារៀងរាល់ឆ្នាំដោយរដ្ឋបាលរាជធានី/ខេត្ត ចំណែក ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ រៀបចំរយៈពេល៥ឆ្នាំម្តង ដោយឡែក កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

ការគ្រោងថវិការបស់រដ្ឋបាលរាជធានី ត្រូវរាប់បញ្ចូលថវិការបស់ រដ្ឋបាលខណ្ឌ និងសង្កាត់ ចំណុះរដ្ឋបាលរាជធានី ដែលបានមកពីការវិភាជ និងការផ្ទេរ ពីមូលនិធិឃុំ/សង្កាត់ និងចំណូលដែលរដ្ឋបាលខណ្ឌ និងសង្កាត់ប្រមូលបានខ្លួនឯង ដោយផ្អែកលើ គោលបំណងនៃគោលនយោបាយ កម្មវិធី អនុកម្មវិធី និងអាទិភាព និងចង្កោមសកម្មភាព ដែលពិពណ៌នាអំពីគោលបំណង និងគោលដៅសូចនាករ ក្របខ័ណ្ឌពេលវេលា និងតម្រូវការថវិកា។ ការបែងចែកថវិកាជូនទៅថ្នាក់ស្រុកនិងក្រុង នៅក្នុងឆ្នាំ២០១៤ មានចំនួន ៦៨ពាន់លានរៀលពោលគឺ ០,៨%នៃចំណូលចរន្តដែលបានគ្រោងទុក។

ការផ្ទេរថវិកាជូនទៅថ្នាក់ឃុំ/សង្កាត់នៅឆ្នាំ២០១៤ មានចំនួន ២៣៧ពាន់លានរៀលពោលគឺ ២,៨%នៃចំណូលចរន្តដែលបានបម្រុងទុក សម្រាប់បែងចែងទៅអោយ មូលនិធិអភិវឌ្ឍន៍ឃុំ/សង្កាត់ ដែលក្នុងនោះថវិកាចំនួន ១០៥ពាន់លានរៀល គឺសម្រាប់ប្រើប្រាស់នៅក្នុងផ្នែករដ្ឋបាល និងចំនួន ១៣២ពាន់លានរៀល គឺសម្រាប់ប្រើប្រាស់នៅក្នុងការអភិវឌ្ឍន៍មូលដ្ឋាន ដែលអាចឱ្យពួកគេ អនុវត្តកានូវអាទិភាពនៃការអភិវឌ្ឍ មូលដ្ឋានរបស់ពួកគេ តាមរយៈថវិកា រៀងៗខ្លួន[6, p.3]។

ការគ្រោងថវិកាក៏ត្រូវឆ្លុះបញ្ចាំងផងដែរនូវ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគខាងលើ ដែលត្រូវដាក់ជូនទៅឲ្យក្រុមប្រឹក្សា រាជធានី/ខេត្ត ពិនិត្យ និងអនុម័ត មុននឹងបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ កំណែទម្រង់ថវិកា គឺមានចរិក លក្ខណៈជាអន្តរវិស័យ ពាក់ព័ន្ធទៅនឹងស្ថាប័ននានា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ពិសេសមានចរិកលក្ខណៈខុសៗគ្នា។ ជាគោលការណ៍ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដឹកនាំ និងសម្របសម្រួល ដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)នៃក្រសួងមហាផ្ទៃ ស្របពេលដែរ កំណែទម្រង់រដ្ឋបាលសាធារណៈ ដឹកនាំ និងសម្របសម្រួល ដោយក្រសួងមុខងារសា ធារណៈ ព្រមជាមួយនឹង កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[13, 14]។

## ២.២. ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

អាស្រ័យតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថវិការឆ្នាំ២០១៦ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបែងចែកជាបីកម្រិតគឺ រដ្ឋបាលរាជធានី/ខេត្ត២៥ រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ២០៣ និងរដ្ឋបាលឃុំ/សង្កាត់ ១៦៤៦។ ក្រុមការងារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបញ្ចូលថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងបី ដែល

[ii] ដំណាក់កាលទី១ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា(មីនា-ឧសភា) និង ដំណាក់កាលទី២ ការរៀបចំកញ្ចប់ថវិកា(មិថុនា-កញ្ញា) និងដំណាក់កាលទី៣ ការអនុម័តថវិកា(តុលា-ធ្នូ)

ទទួលបានការបែងចែកថវិកាពីនាយកដ្ឋានហិរញ្ញវត្ថុ រដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅក្នុងប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ បន្ថែមពីលើនេះទៀត រតនាគាររាជធានី/ខេត្ត នឹងបញ្ចូលថវិការ លំអិតសម្រាប់រដ្ឋបាលឃុំ/សង្កាត់ ទៅតាមគម្រោងថវិការបស់ខ្លួនដែលបានស្នើឡើងជាបណ្តោះអាសន្ន[15]។

គោលដៅនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺដើម្បីបង្កើនថវិកាដល់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ ដោយការកសាងសមត្ថភាព និងក្របខ័ណ្ឌគណនេយ្យភាពច្បាស់លាស់ ស្របពេលដែរ ការអនុវត្តថវិកា ចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើង តាមរយៈ ការធ្វើឱ្យនីតិវិធីទូទាត់ថវិកា គណនេយ្យភាព និងប្រព័ន្ធត្រួតពិនិត្យ និងតាមដាន កាន់តែសាមញ្ញឡើង[13]។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំបង្កើន កញ្ចប់ថវិកាបន្ថែមចំនួន ០.១% ប្រចាំឆ្នាំជូន រដ្ឋបាលក្រុង/ស្រុក និងឃុំ/សង្កាត់ ដោយក្នុងនោះ មូលនិធិក្រុង/ស្រុក ត្រូវដំឡើងពី១.១% នៅឆ្នាំ២០១៩ ទៅ ១.៥% នៅឆ្នាំ២០២៣ និងមូលនិធិឃុំ/សង្កាត់ ត្រូវដំឡើងពី៣% នៅឆ្នាំ២០១៩ ទៅ ៣.៤% នៅឆ្នាំ២០២៣នៃចំណូលចរន្តថវិកាថ្នាក់ជាតិដែលបានអនុម័តឆ្នាំមុន[13]។

*រូបភាព 2៖ កម្រិតនៃការវិភាជន៍ថវិកាពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ*




*ប្រភព៖ រាជរដ្ឋាភិបាលកម្ពុជា (២០១៩) យុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ*

បន្ថែមលើនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រកាសបែងចែក ចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី/ខេត្ត ទៅឲ្យរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ ៣% និងរដ្ឋបាលឃុំ/សង្កាត់ ១% សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន[13]។ ចុងបញ្ចប់ ព័ត៌មានស្តីពីថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការវិភាជសមាសភាគវិនិយោគសាធារណៈប្រចាំឆ្នាំ ត្រូវផ្អែកតាមរូបមន្ត និងលក្ខខណ្ឌវិនិច្ឆ័យ ដែលកំណត់ដោយក្រុមប្រឹក្សាភិបាលគ្រប់គ្រង មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ(ក.វ.ក) សម្រាប់វាយតម្លៃសំណើរគម្រោងវិនិ-យោគជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ បានមកពីប្រភពចំនួនបី៖ ទី១ ហិរញ្ញប្បទានចំណូលចរន្តនៃថវិកាជាតិ សម្រាប់គម្រោងវិនិយោគសាធារណៈ សមាសភាគវិនិយោគសាធារណៈ និងសមាសភាគចំណាយប្រតិបត្តិការ រដ្ឋបាលទូទៅនៃលេខាធិការដ្ឋាន ក.វ.ក ទី២ ដៃគូអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញ-វត្ថុអន្តរជាតិ និងទី៣ ប្រភពចំណូលពីដៃគូអភិវឌ្ឍន៍នានា[13, 16]។

## ២.៣. បញ្ហាប្រឈមនៃការបែងចែកថវិកា

ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា តម្រូវដោយមានការផ្សារភ្ជាប់ នូវថវិកាតាមគោលនយោបាយយ៉ាងរឹងមាំមួយ នៅក្នុងការបែងចែងធនធាន រយៈពេលមធ្យម[17, p.8-9] ដែលផែនការនេះ មិនទាន់បានធ្វើសមាហរណកម្ម ភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រថ្នាក់ក្រោមជាតិ និងក៏មិនទាន់បាន ធ្វើការតម្រឹមជាមួយនឹងផែនការយុទ្ធសាស្ត្រនៃមន្ទីរជំនាញរាជធានីខេត្តនៅឡើយ។ មួយវិញទៀត ផែនការ និងកម្មវិធី សម្រាប់ ថវិការដ្ឋបាល

ថ្នាក់ក្រោមជាតិ និងថវិកាមន្ទីជំនាញរាជធានី/ខេត្ត ពុំទាន់មានការប្រឹក្សាយោបល់គ្នា និងសហការគ្នាឲ្យបានគ្រប់គ្រាន់រវាង ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធនៅឡើយ[13]។

យ៉ាងណាមិញ ផ្អែកតាមបទពិសោធន៍ និងក្របខ័ណ្ឌពេលវេលា សម្រាប់ការផ្លាស់ប្តូរពីប្រព័ន្ធ"ថវិកាតាមកម្មវិធី" ទៅប្រព័ន្ធ"ថវិកាព័ត៌មានសមិទ្ធកម្ម" កំណែទម្រង់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ជួបប្រទះនឹងការលំបាក ទាំងសមត្ថភាព និងធនធាន និងមិនទាន់អាចសំរេចបាននៅត្រឹមឆ្នាំ២០២៥បានឡើយ[13]។ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មិនបានគាំទ្រដំណើរការនេះដោយរលូននោះទេ និងតំរូវអោយមានវិធីសាស្រ្ត ការចូលរួមពីសាធារណៈជន និងមានរបៀបរៀបរយ រួមបញ្ចូលទាំងការត្រួតពិនិត្យច្បាប់ យ៉ាងត្រឹមត្រូវ និងបានទាន់ពេលវេលា ក៏ដូចជាព័ត៌មានដែលអាចទុកចិត្តបាន និងទាន់ពេលវេលា ដែលគេបានផ្តល់ត្រលប់មកវិញស្តីពីថវិកាដែរបានផ្ទេរទៅឃុំ/សង្កាត់ ដែលរៀបចំថវិកាផ្ទាល់ខ្លួនដោយឯករាជ្យ។ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម មិនត្រូវបានបង្កើត និងបញ្ចូលទៅក្នុងដំណើរការរៀបចំផែនការថវិកាពេញលេញនៅឡើយ ដោយមានទំនាក់ទំនងច្បាស់លាស់ពីវដ្តថវិកាមួយទៅមួយវដ្តថវិកាមួយទៀត [17, p.8-9]។

បញ្ហាមួយទៀត គឺទាក់ទងទៅនឹងការធ្វើចំណាត់ថ្នាក់ថវិកា ដែលប្រើប្រាស់សំណុំនៃស្លាកលេខ សម្រាប់ការវិភាគចំណូលចំណាយថវិកា និងការទូទាត់/ប្រភព និងដែលប្រើប្រាស់មូលនិធិនៅក្នុងចំណាត់ថ្នាក់នីមួយៗ។ រដ្ឋាភិបាល បានរៀបចំកម្រងវិជ្ជមាត្រយ៉ាងទូលំទូលាយ និងការពិពណ៌នាអំពីចំណាត់ថ្នាក់ដើម្បីដាក់បញ្ចូលឬប្រើប្រាស់នៅក្នុងគម្រោងទាំងនោះ ដោយអ្នកពាក់ព័ន្ធនានា ជាមួយនឹងលេខកូដ និងការពិពណ៌នាអំពីចំណាត់ថ្នាក់ទាំងនោះផងដែរ [17, p.8-9]។ ទោះយ៉ាងណាក៏ដោយ ការត្រួតពិនិត្យ លើការបែងចែកថវិកា និងការប្រើប្រាស់ថវិកា ត្រូវបានចុះ-ខ្សោយដោយកង្វះខាតនៃតារាងគណនី ដែលឆ្លុះបញ្ចាំងពីចំណាត់ថ្នាក់ផ្អែកលើវិស័យមុខងារ និងកម្មវិធី និងកង្វះខាតនៃរបាយការណ៍លម្អិត ស្តីពីការអនុវត្តគម្រោងដែលទទួលបានមូលនិធិពីខាងក្រៅ ដែលបង្កើតបានជា ការវិនិ- យោគសាធារណៈ ៣ភាគ៤ផងដែរ ព្រមជាមួយនឹង ប្រព័ន្ធដ៏ខ្សោយ ដើម្បីតាមដាន ថាតើធនធានបានដល់អង្គភាពផ្តល់សេវាសាធារណៈដល់កំរិតណា[6, p.3]។ ជាលទ្ធផល ការបែងចែកធនធានជាក់ស្តែង កំឡុងពេល អនុវត្តថវិកា មាននិន្នាការងាកចេញពី គោលដៅនៃគោលនយោបាយយ៉ាងខ្លាំង ដែលបានឆ្លុះបញ្ចាំងនៅក្នុងសំណើរថវិការបស់ រដ្ឋាភិបាល ដែលជាទូទៅ ត្រូវបានអនុម័តដោយអង្គនីតិបញ្ញត្តិ ដោយមានការធ្វើវិសោធនកម្មតិចតួចបំផុត[6, p.3]។

## ២.៤. ការម្រងច្បាប់ និងក្របខណ្ឌយុទ្ធសាស្រ្តនៃការកែទម្រង់ប្រព័ន្ធថវិកា

ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងក្របខ័ណ្ឌយុទ្ធសាស្រ្តថវិកាទាំងអស់ ផ្តល់ជាគោលការណ៍ណែនាំលក្ខណៈបច្ចេកទេស ជាផែនទីចង្អុលផ្លូវ និងទំនួលខុសត្រូវផ្អែកគតិយុត្ត សម្រាប់ក្នុងការផ្ទេធនធាន ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ឯកសារគតិយុត្តទាំងនោះ ក៏លើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការ ជាអាទិភាព របស់ប្រជាពលរដ្ឋ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋាភិបាលថ្នាក់កណ្តាល បានផ្ទេរមុខងារជាបណ្តើរៗ និងបានធ្វើប្រតិភូកម្ម ការទទួលខុសត្រូវ ក្នុងលក្ខណៈជាការអនុវត្តសាកល្បងជូនដល់ថ្នាក់ក្រោមជាតិ[5, 13, 18]។ ជាលទ្ធផល ភ្នាក់ងាររដ្ឋាភិបាល ទាំងថ្នាក់ជាតិ និង

ថ្នាក់ក្រោមជាតិ បានវិវឌ្ឍខ្លួន អោយក្លាយជាមន្ត្រីរាជការ ដែលសកម្ម ឆ្លើយតបទាន់ពេលវេលា មានប្រសិទ្ធភាព ខ្ពស់ និង ដែលអាចជឿជាក់បាន តាមរយៈ ការផ្តល់គុណភាពខ្ពស់ និងសេវាសាធារណៈដ៏ប្រសើរ ទៅអោយអ្នក ប្រើប្រាស់សេវា ដែលធានាបាននូវ តម្លាភាព គណនេយ្យភាព ភាពងាយស្រួល ភាពបើកចំហ ការចូលរួម និង សមភាព សម្រាប់ប្រជាពលរដ្ឋទូទៅ[19, 20, 21, 22] ពិសេសពង្រឹងគណនេយ្យភាព ឃុំ/សង្កាត់សម្រាប់ការ អភិវឌ្ឍន៍មូលដ្ឋាន បន្ទាប់ពីការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ២០០៨ [23]។

ជាក់ស្តែង កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៤ មានគោលបំណងប្រែក្លាយប្រព័ន្ធ ហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ឲ្យទៅជាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ក្នុងកម្រិតឧត្តមានុវត្តន៍ និងស្តង់ដារអន្តរ ជាតិនៅឆ្នាំ២០២៥៕ ជាសមទ្ធិផល ដំណាក់កាលទី១(២០០៥-២០០៨) និងដំណាក់កាលទី២(២០០៩-២០១៥) ត្រូវបានបញ្ចប់ ដំណាក់កាលទី៣(២០១៦-២០២០)កំពុងអនុវត្ត និងដំណាក់កាលទី៤(២០២១-២០២៥)ត្រូវបានកំណត់ជាស្រេច[6]។

ទន្ទឹមគ្នានេះដែរ ការផ្តល់សេវាកាន់តែប្រសើរសម្រាប់ពលរដ្ឋ ទាមទារស្តង់ដារសេវាកម្មសាធារណៈខ្ពស់ជាងមុន ពាក់ព័ន្ធនឹងធនធានមនុស្ស និងប្រព័ន្ធបង់ប្រាក់[20]។ ការកែលម្អធនធានមនុស្ស ទាក់ទងនឹងសមត្ថភាព របស់ មន្ត្រីរាជការ គឺជាសមាសធាតុស្នូល សម្រាប់ការធ្វើផែនការ ការសម្របសម្រួល និងតាមដានការអនុវត្តកំណែ ទម្រង់រដ្ឋបា-ល[22]។

ជាក់ស្តែង ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារ ណៈ ឆ្នាំ២០០៨ បានផ្តល់ជាក្របខ័ណ្ឌយុទ្ធសាស្ត្រ ប្រែក្លាយប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមគោល ការណ៍ (រដ្ឋបាលឯកភាព) ដើម្បីបង្កើន ជំរុញ និងធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈការកំណត់តួនាទី មុខងារ និងសិទ្ធិអំណាចទៅតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាលទ្ធផល ការ ផ្តល់សេវាសា- ធារណៈ បាននឹងកំពង់អភិវឌ្ឍបានបណ្តើរៗនៅថ្នាក់ក្រោមជាតិ មានដូចជា៖ ប្រព័ន្ធគ្រប់គ្រង ធនធានមនុស្ស ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងរាយការណ៍ ត្រូវបានកែលម្អ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និង ប្រព័ន្ធកសាងផែនការ ត្រូវបានបង្កើតឡើយ ប្រព័ន្ធទំនាក់ទំនងការងារលក្ខណៈអន្តររដ្ឋបាល ត្រូវបានអនុវត្ត និងយន្តការផ្តល់សេវាតាមច្រកចេញចូលតែមួយ និងយន្តការទទួល និងដោះស្រាយបណ្តឹងតវ៉ារបស់ប្រជា ពលរដ្ឋ ព្រមទាំង បែបបទ និងនីតិវិធីបំពេញការងារ ត្រូវបានបង្កើតឡើង និងដាក់អោយដំណើរ។

បន្ថែមពីលើនេះ ឯកសារទស្សនទាន ស្តីពីទិសដៅយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិការកម្ពុជា (២០១៣-២០២០) មានគោលដៅផ្លាស់ប្តូរជាជំហានៗ ពីប្រព័ន្ធថវិកាផ្អែកលើធាតុចូល និងមជ្ឈការ ទៅរកប្រព័ន្ធថវិកា ផ្អែកលើសមិទ្ធកម្ម និងវិមជ្ឈការ ត្រឹមឆ្នាំ២០២០ តាមរយៈការពង្រឹងការផ្សាភ្ជាប់ថវិកា ទៅនឹងគោល នយោបាយ និងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកា តាមកម្មវិធីសម្រាប់ក្រសួង ស្ថាប័ន និងរដ្ឋបាល រាជធានី ខេត្ត។ ម្យ៉ាងវិញទៀត អនុក្រិត្យលេខ៣២ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាល ថ្នាក់ក្រោមជាតិ ចុះថ្ងៃទី២៩ កុម្ភៈ ២០១៦ សំដៅលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច ការបំពេញភារៈកិច្ច និងការ

គ្រប់គ្រងការវិនិយោគសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈហិរញ្ញប្បទានមានលក្ខណៈជាយុទ្ធសាស្ត្រ។ ស្របពេលដែរ អនុក្រិត្យលេខ០៦ស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិចុះថ្ងៃទី៥ មករា ២០១៧ ចូលរួមផ្តល់យន្តការសម្របសម្រួល និងគ្រប់គ្រងហានិភ័យនៃការប្រគល់ និងការធ្វើប្រតិភូកម្មមុខងារទៅថ្នាក់ក្រោមជាតិ[13]។

សរុបមកយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា(២០១៨-២០២៥) និងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ(២០១៩-២០២៥) គឺជាប្រទីបចង្អុលបង្ហាញផ្លូវ សម្រាប់ផ្លាស់ប្តូរប្រព័ន្ធថវិកាឆ្ពោះទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម[13, 14, 24]។

## III. សេចក្តីសន្និដ្ឋាន

ឃុំ/សង្កាត់បានទទួលតួនាទី ទំនួលខុសត្រូវ និងការបែងចែកថវិកាបន្ថែមកាន់តែច្រើនជាងមុន។ បន្ថែមពីលើការធ្វើផែនការអភិវឌ្ឍឃុំ/សង្កាត់រយៈពេល ប្រាំឆ្នាំ និងកម្មវិធីវិនិយោគឃុំ/សង្កាត់រយៈពេល បីឆ្នាំ ឃុំ/សង្កាត់ត្រូវផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សហគម-ន៍។ រដ្ឋាភិបាលកម្ពុជាបានបង្កើតច្បាប់ ក្របខ័ណ្ឌយុទ្ធសាស្ត្រជាច្រើន ព្រមទាំងបានផ្តល់ការណែនាំបច្ចេកទេសក៏ដូចជាបង្ហាញផ្លូវច្បាស់លាស់ ក្នុងការគាំទ្រដល់កម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគាំទ្រផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគឃុំ/សង្កាត់។ យុទ្ធសាស្ត្រនៃការបង្វែរពីប្រព័ន្ធថវិកាផ្អែកលើធាតុចូល និងមជ្ឈការ ទៅរកប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម និងវិមជ្ឈការ ក្នុងគោលបំណងផ្សារភ្ជាប់ថវិកា ទៅនឹងគោលនយោបាយ និងការបែង-ចែកធនធាន និងការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ដោយភាពជឿជាក់ ប្រសិទ្ធភាព និងការឆ្លើយតបទាន់ពេលវេលាទៅនឹងបញ្ហា នៅតែជាបញ្ហាដែលត្រូវដោះស្រាយ និងត្រូវការចំណាយពេលយូដើម្បីសម្រេចបាន។

លើសពីនេះទៅទៀត ការបែងចែកថវិកាប្រកបដោយប្រសិទ្ធភាព ទាមទារឲ្យមានការបញ្ចូលផែនការយុទ្ធសាស្ត្រថវិកា និងផែនការយុទ្ធសាស្ត្រថ្នាក់ក្រោមជាតិ (ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគមូលដ្ឋាន) តាមរយៈការពិគ្រោះយោបល់ញឹកញាប់ ក្នុងចំណោមភាគីពាក់ព័ន្ធនានា ស្របពេលដែរ ការកសាងសមត្ថភាពធនធានមនុស្ស ស្តីពីវិធីអភិវឌ្ឍផែនការយុទ្ធសាស្ត្រថ្នាក់ក្រោមជាតិ ឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រថវិកា អាស្រ័យគោលនយោបាយ គួរត្រូវបានយកចិត្តទុកដាក់ផងដែរ។ នីតិវិធីបែងចែកថវិកា គួរតែធ្វើឡើងដោយសាមញ្ញ ពាក់ព័ន្ធនឹងនីតិវិធីនៃការទូទាត់ (ប្រើប្រព័ន្ធធនាគារសម្រាប់ការបែងចែកថវិកា ព្រមទាំងវិក័យប័ត្រនឹងការទូទាត់ថវិកា) ក្របខ័ណ្ឌគណនេយ្យភាពច្បាស់លាស់គួរត្រូវបានបង្កើតឡើង ហើយប្រព័ន្ធតាមដាន និងត្រួតពិនិត្យ (ជំនាញឱជីថល ប្រព័ន្ធវាយតំលៃ) គួរតែត្រូវអនុវត្តយ៉ាងទូលំទូលាយ។ បន្ថែមលើនេះ ដើម្បីដោះស្រាយបញ្ហាប្រឈមរបស់ឃុំ/សង្កាត់ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ការគាំទ្របន្ថែមលើផ្នែកហិរញ្ញវត្ថុ ការកសាងសមត្ថភាព និងកិច្ចសហការកាន់តែច្រើនពីអ្នកពាក់ព័ន្ធ តម្រូវអោយមានដោយខានមិនបាន។ ទោះបីជា កង្វះខាតនូវទិន្នន័យ/ព័ត៌មាន ស្តីពីផែនការអភិវឌ្ឍន៍មូល ដ្ឋាន និងការបែងចែកថវិកាសម្រាប់ខេត្ត

មណ្ឌលគិរីក៏ដោយ ក៏ក្រសួង/មន្ទីរ និងអង្គការក្រៅរដ្ឋាភិបាល គួរតែត្រៀមខ្លួន ចែករំលែកបទពិសោធន៍របស់ពួកគេក្នុងការរៀបចំថវិកា និងផែនការអភិវឌ្ឍ ក្នុងកម្រិតការងាររបស់ពួកគេ។

# ឯកសារយោង


1. Royal Government of Cambodia, (2013). *Economic census report: provincial report Mondul Kiri province*. Phnom Penh, Cambodia: National Statistic Institute, Ministry of Planning.
2. Royal Government of Cambodia, (2019). *General Population Census of the Kingdom of Cambodia 2019: Provincial Population Totals*. Phnom Penh, Cambodia: National Institute of Statistic, Ministry of Planning
3. Royal Government of Cambodia. (2001 ). *Law on Administrative Management of the Commune/Sangkat* Cambodia, Available at: http://www.skpcambodia.com/Laws%20&%20Regulations%20of%20the%20Kingdom%20of%20Cambodia/Property%20&%20Land%20Law/LAW-01-Commune%20Administration-E.pdf [Accessed 10 Oct. 2019].
4. Royal Government of Cambodia. (2008). *Law on the administrative management of Capital, Provinces, Municipalities, Districts and Khans* [Art. 36] Phnom Penh, Cambodia, Available at: http://www.cdc-crdb.gov.kh/cdc/twg_network/country_systems_cambodia/strengthening_national_systems/documents_for_reform/sndd/organic_law_2008_en.pdf [Accessed 10 Oct. 2019].
5. រាជរដ្ឋាភិបាលកម្ពុជា, (២០១៧). សេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំសង្កាត់. ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា: គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ.
6. Steering Committee of the Public Financial Management Reform. (2015). *Report of the Evaluation on the Public Financial Management System of Cambodia: Based on Public Expenditure and Financial Accountability Methodology.* Phnom Penh, Cambodia: General Secretariat of Steering Committee of the Public Financial Management Reform.
7. COMFREL. (2013). *Assessment of the second term of decentralization in Cambodia:Commune Council Performance and Citizens' Participation, 2007-2012.* Phnom Penh, Cambodia: COMFREL, Available at: https://comfrel.org/english/wp-content/uploads/2018/05/225_Final_report_of_the_Second_Term_of_DD_English.pdf [Accessed 04 Oct. 2019].
8. រាជរដ្ឋាភិបាលកម្ពុជា. (២០១៧). សេចក្តីនែនាំ ស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ. ភ្នំពេញ ក្រសួងផែនការ និងក្រសួងមហាផ្ទៃ,, Available at: http://ncdd.gov.kh/wp-content/uploads/2018/10/4.-Khan-DP.pdf [Accessed ១០ តុលា ២០១៩].
9. ADB. (2017). *Guidelines for mainstreaming disaster risk reduction in to sub-national development plans* [online] Phnom Penh, Cambodia: ADB, Available at: http://adbproject.ncdm.gov.kh/Home/GetPdf?fileName=TA8669_Guidelines_on_Mainstreaming_DRR_into_sub_national_development_plans_final.pdf [Accessed 11 Oct. 2019].
10. Mom, V. and Xu, X. (2016). Commune/Sangkat Fund and Local Development: Case of Cambodia *Journal of Economics and Sustainable Development* [online] 7(22). Available at: https://iiste.org/Journals/index.php/JEDS/article/view/34185 [Accessed 10 Oct. 2019].
11. Transparency International Cambodia. (2018). *Accountability and transparency of budget process: national survey.* [pdf] Phnom Penh, Cambodia: Transparency International Cambodia, Available at: http://ticambodia.org/library/wp-content/files_mf/1526534245FullreportonAccountabililtyandTransparencyofBudgetProcess.pdf [Accessed 10 Oct. 2019].
12. Inter-ministerial Working Group. (2007). *Guideline on C/S Development Plan and C/S Investment Program.* [online] Phnom Penh, Cambodia: Royal Government of Cambodia, Available at: https://www.cncc.gov.kh/userfiles/image/download/Guidelines%20&%20Decisions-

F14%20Guidelines%20on%20Commune.Sangkat%20Development%20%20&%20Investment%20Plan-En.pdf [Accessed 03 Oct. 2019].

13. រាជរដ្ឋាភិបាលកម្ពុជា, (២០១៩). យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥:ប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព. ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា: គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ.

14. រាជរដ្ឋាភិបាលកម្ពុជា, (២០១៩). សារាចរណែនាំ ស្ដីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២. ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា: រាជរដ្ឋាភិបាលកម្ពុជា.

15. ADB. (2018). *FISCAL DECENTRALIZATION REFORM IN CAMBODIA: PROGRESS OVER THE PAST DECADE AND OPPORTUNITIES.* Manila, Philippines.

16. រាជរដ្ឋាភិបាលកម្ពុជា, (២០១៧). អនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ. ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា.

17. Royal Government of Cambodia, (2012). *Financial management manual:For All Externally Financed Projects/Programs in Cambodia*. Phnom Penh, Cambodia.

18. រាជរដ្ឋាភិបាលកម្ពុជា, (២០១៧). សេចក្ដីណែនាំបច្ចេកទេស ស្ដីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខណ្ឌ. ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា: គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ.

19. Neb, S. (2017). One Window Service Offices: Improving Government Transparency and Responsiveness. *Social Science Asia,* 3(n.a), pp. 12-24.

20. Neang, L. (2018). Public Service Improvement "Public Service Standards" Cambodian Experience. In: *First Regional Workshop for Developing ASEAN Guideline on Public Service Delivery*, Empress Angkor Hotel, SiemReap: Ministry of Civil Service.Available at.: http://www.mcs.gov.kh/files/WorkshopASEAN/Representatives_of_Cambodai.pdf [Accessed 01 Oct. 2019].

21. Ministry of Economy and Finance, (2017). *Economic and Financial Public Service Compendium*. Phnom Penh, Cambodia: General Secretariat.

22. Christoph, B. (2014). *Decentralisation and administrative reform programme.* Deutsche Gesellschaft für Internationale Zusammenarbeit (GIZ).

23. Khoun, T. (2018). Fiscal decentralisation and good governance: convergence or divergence? The experience of commune councils in Cambodia. *Asia Pacific Journal of Public Administration,* 40(2), pp. 115-131.

24. រាជរដ្ឋាភិបាលកម្ពុជា, (២០១៩). ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩- ២០២៣: ដើម្បីកំណើន បង្កើតការងារ ជានាសមធម៌ និងប្រសិទ្ធភាពឆ្ពោះទៅប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ឆ្នាំ២០៣០. ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា.

# ឧបសម្ពន្ធ័

*ផែនទី 1៖ តំបន់រដ្ឋបាលខេត្ត មណ្ឌលគីរី តាម ស្រុក ឃុំ*




**Code of Province / Municipality, District, and Commune**

**11 MONDUL KIRI**

**1101 Kaev Seima**
110101 Chong Phlah
110102 Memang
110103 Srae Chhuk
110104 Srae Khtum
110105 Srae Preah

**1102 Kaoh Nheaek**
110201 Nang Khi Lik
110202 A Buon Leu
110203 Roya
110204 Sokh Sant
110205 Srae Huy
110206 Srae Sangkum

**1103 Ou Reang**
110301 Dak Dam
110302 Saen Monourom

**1104 Pech Chreada**
110401 Krang Teh
110402 Pu Chrey
110403 Srae Ampum
110404 Bu Sra

**1105 Saen Monourom**
110501 Monourom
110502 Sokh Dom
110503 Spean Mean Chey
110504 Romonea

* Codes and boundaries are as of September 7, 2009.

*ប្រភព៖ វិទ្យាស្ថានស្ថិតិជាតិ ឆ្នាំ ២០១៣, ជម្រើនសេដ្ឋកិច្ច ២០១១៖ ខេត្តមណ្ឌលគីរី*